១.	លោក	**ង៉ែត សារ៉ែម**	មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន
២.	លោកស្រី	**ហាស់ សាវន**	មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន
៣.	លោកស្រី	**សួយ សុវណ្ណនី**	មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន
៤.	លោកស្រី	**ឌួន ច័ន្ទផល្លី**	មានឋានៈស្មើ **អគ្គនាយករង** បន្ថែមលើមុខងារបច្ចុប្បន្ន
៥.	លោក	**សំរិទ្ធ លាបហោច**	មានឋានៈស្មើ **អគ្គនាយករង**
៦.	លោកស្រី	**តូច ស៊ីយ៉ា**	មានឋានៈស្មើ **អគ្គនាយករង**
៧.	លោកស្រី	**ហ៊ុយ ធីម**	មានឋានៈស្មើ **អគ្គនាយករង**
៨.	លោកស្រី	**ទុំ ស្រីលៀម**	មានឋានៈស្មើ **អគ្គនាយករង**
៩.	លោកស្រី	**ឌឹម សុលីដែន**	មានឋានៈស្មើ **អគ្គនាយករង**

១០.	លោក	**អ៊ុន សំអូន**	មានឋានៈស្មើ **អគ្គនាយករង**
១១.	លោក	**ម៉ៃ គីមឡេង**	មានឋានៈស្មើ **អគ្គនាយករង**
១២.	លោក	**ងឹង ទី**	មានឋានៈស្មើ **អគ្គនាយករង**
១៣.	លោក	**សូ សំអាត**	មានឋានៈស្មើ **អគ្គនាយករង**
១៤.	លោក	**សាន់ ស៊ីន**	មានឋានៈស្មើ **អគ្គនាយករង**
១៥.	លោក	**គួច បញ្ញា**	មានឋានៈស្មើ **អគ្គនាយករង**
១៦.	លោក	**ពៅ ពិសាល**	មានឋានៈស្មើ **អគ្គនាយករង**
១៧.	លោក	**សរ ពិសិដ្ឋ**	មានឋានៈស្មើ **អគ្គនាយករង**
១៨.	លោក	**គួច សុភាព**	មានឋានៈស្មើ **អគ្គនាយករង**
១៩.	លោកស្រី	**គួច មាល័យ**	មានឋានៈស្មើ **អគ្គនាយករង**
២០.	លោកស្រី	**អ៊ឹង សុខម៉ីយ**	មានឋានៈស្មើ **អគ្គនាយករង**
២១.	លោកស្រី	**អ៊ុន ស៊ីណែត**	មានឋានៈស្មើ **អគ្គនាយករង**
២២.	លោក	**យ៉ាង ចាន់ណា**	មានឋានៈស្មើ **អគ្គនាយករង**
២៣.	លោក	**ឈឹន ចន្ថា**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
២៤.	លោក	**ឆូ កុសល**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
២៥.	លោក	**ចាន់ រ៉ាឌី**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
២៦.	លោកស្រី	**ហេង សុភាព**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
២៧.	លោកស្រី	**ព្រហ្ម ដានិច្ច**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
២៨.	លោក	**ឌី ពេជ្របញ្ញា**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
២៩.	លោកស្រី	**រឿម សុខលឿត**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៣០.	លោកស្រី	**ចិន មូលីកា**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៣១.	លោកស្រី	**ស៊ីន សុម៉ាលីរ័ត្ន**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៣២.	លោក	**សោភ័ណ សុផាន់ណា**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៣៣.	លោកស្រី	**ឡៅ ធីតា**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**
៣៤.	លោក	**ទឹម ពិសិដ្ឋ**	មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៩០ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ និងចីរប្រឹក្សា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

មាត្រា ១.-

តែងតាំងមន្ត្រីរាជការអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានរាយនាមខាងក្រោម÷

១. លោក **កែវ សុខឃាង** បច្ចុប្បន្នជាប្រធាននាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

២. លោក **សុខ សុជាវ៉ា** បច្ចុប្បន្នជាប្រធានសាខាគយ និងរដ្ឋាករខេត្តសៀមរាប ជាប្រធាននាយកដ្ឋានតំបន់រួចពន្ធ

៣. លោក **គាំ ចំន្ទកុសល** បច្ចុប្បន្នជាអនុប្រធាននាយកដ្ឋានផែនការ និងបច្ចេកទេស ជាប្រធានលេខាធិការដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២.-

តែងតាំងទីប្រឹក្សាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដូចមានរាយនាមខាងក្រោម÷

១. លោក **ហ៊ីវ គឹមហេង** មានឋានៈស្មើ អគ្គនាយករង

២. លោក **ខៀវ សំអាន** មានឋានៈស្មើ អគ្គនាយករង

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩ រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨៤ ខែ កក្កដ ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ÷

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៣ សសរ

សេចក្តីសម្រេច
ស្តីពី
ការបង្កើតគណៈកម្មការអន្តរក្រសួង
ដើម្បីរៀបចំពិធីបុណ្យសមុទ្រលើកទី៨ ជុំទី២ នៅខេត្តកំពត
ពីថ្ងៃទី២០ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៧៦ អនក្រ.បក ចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់ពិធីបុណ្យសមុទ្រ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

សម្រេច

ប្រការ១ .-

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិធីបុណ្យសមុទ្រលើកទី៨ ជុំទី២ នៅខេត្តកំពត ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២០ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩ ក្រោមប្រធានបទ **ទីក្រុងស្អាត ឆ្នេរល្អ ទេសចរណ៍រុងរឿង** ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ថោង ខុន**	រដ្ឋមន្ត្រីក្រសួងទេសចរណ៍	ប្រធាន
២- ឯកឧត្តម **ជាវ តាយ**	អភិបាលនៃគណៈអភិបាលខេត្តកំពត	អនុប្រធានអចិន្ត្រៃយ៍
៣- ឯកឧត្តម **ទិត ចន្ថា**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
៤- ឯកឧត្តម **ជា ម៉ូរ៉ា**	រដ្ឋលេខាធិការក្រសួងទេសចរណ៍	អនុប្រធាន
៥- ឯកឧត្តម **អ៊ុក សុជាតិ**	រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	អនុប្រធាន
៦- ឯកឧត្តម **ឈួន ជារ៉ា**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	អនុប្រធាន
៧- ឯកឧត្តម **សាន់ សាប់អឺ**	រដ្ឋលេខាធិការក្រសួងសុខាភិបាល	សមាជិក
៨- ឯកឧត្តម **ទូ សុវត្ថិ**	រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន	សមាជិក
៩- ឯកឧត្តម **សំ សិរីរតន៍**	រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម	សមាជិក
១០- ឯកឧត្តម **ហាស់ សាវ៉ែត**	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១១- ឯកឧត្តម **ណូ សម្បុក**	ទីប្រឹក្សាអមគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ	សមាជិក
១២- ឯកឧត្តម **ប៉ូ រតនា**	អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក
១៣- ឯកឧត្តម **សុត យ៉ា**	អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន	សមាជិក
១៤- ឯកឧត្តមនាយឧត្តមសេនីយ៍ **ហ៊ឹម យ៉ាន**	អគ្គស្នងការរងនគរបាលជាតិ	សមាជិក
១៥- ឯកឧត្តមនាយឧត្តមសេនីយ៍ **ទូច ណារ៉ុថ**	អគ្គស្នងការរងនគរបាលជាតិ	សមាជិក
១៦- ឯកឧត្តមឧត្តមសេនីយ៍ឯក **យិន តា**	អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍	សមាជិក
១៧- លោកឧត្តមសេនីយ៍ឯក **ម៉ន សាម៉ុន**	មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
១៨- លោក **ឆួន ច័ន្ទរិទ្ធ**	អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា	សមាជិក
១៩- លោក **ហ៊ុលក្រុង ផារណង**	អនុប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ	សមាជិក។

ប្រការ២ .-

គណៈកម្មការអន្តរក្រសួងនេះមានតួនាទីនិងភារកិច្ចដឹកនាំ ចាត់ចែង និងត្រួតពិនិត្យដំណើរការរៀបចំពិធីបុណ្យសមុទ្រលើកទី៨ ជុំទី២ នៅខេត្តកំពត ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២០ដល់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៩។

ប្រការ៣ .-

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាសេនាធិការ និងអនុគណៈកម្មការអន្តរក្រសួងមួយចំនួនតាមការចាំបាច់ ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

ប្រការ៤ .-

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើថវិការបស់ក្រសួងទេសចរណ៍និងប្រភពថវិកាស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន។

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់និងឧបត្ថម្ភបន្ថែមដល់ដំណើរការរៀបចំពិធីបុណ្យសមុទ្រឆ្នាំ២០១៩។

ប្រការ៥ .-

គណៈកម្មការអន្តរក្រសួងនេះមានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់។

អនុប្រធាននិងសមាជិកនៃគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង។

ក្នុងករណីចាំបាច់ ប្រធានគណៈកម្មការអន្តរក្រសួងអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន និងអ្នកជំនាញពាក់ព័ន្ធផ្សេងៗទៀត ចូលរួមកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួង។

ប្រការ៦ .-

គណៈកម្មការអន្តរក្រសួងនេះនឹងត្រូវរំសាយក្រោយពេលចប់ការកិច្ច។

ប្រការ៧ .-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៨ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០៣២៦.ន៩.អ៩.ប្រក

ប្រកាស
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅ
នៃការិយាល័យចំណុះឱ្យនាយកដ្ឋាននានានៃអគ្គនាយកដ្ឋានថាមពល

រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខដំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័ន និងថ្នាក់ក្រោមជាតិ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល

សម្រេច
ដំឡូកទី១
បទប្បញ្ញត្តិទូទៅ

ប្រការ១ ..

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានថាមពល។

ប្រការ២ ..

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានថាមពល
- រៀបចំតួនាទីនិងភារកិច្ចនៃការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានថាមពល និង
- ធានាគុណភាពនិងប្រសិទ្ធភាពនៃការដឹកនាំ គ្រប់គ្រង និងលទ្ធផលបំពេញការងារ។

ប្រការ៣ ..

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់ការិយាល័យចំណុះឱ្យនាយកដ្ឋាននៃអគ្គនាយកដ្ឋានថាមពល។

ជំពូកទី២
បេសកកម្មនិងរចនាសម្ព័ន្ធ

ប្រការ៤ ..

អគ្គនាយកដ្ឋានថាមពលបំពេញមុខងារជាសេនាធិការឱ្យក្រសួងរ៉ែនិងថាមពលដែលមានបេសកកម្មគ្រប់គ្រងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី។

ប្រការ៥ ..

អគ្គនាយកដ្ឋានថាមពលមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងកំណត់គោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ បទប្បញ្ញត្តិ និងស្តង់ដារ ក្នុងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- ជំរុញការកសាងសមត្ថភាពធនធានមនុស្សនិងការផ្ទេរបច្ចេកវិទ្យាក្នុងវិស័យថាមពល ផ្នែកបរមាណូស៊ីវិល រួមទាំងវិទ្យុសកម្ម និងអគ្គិសនី
- ធ្វើកិច្ចសហប្រតិបត្តិការក្នុងវិស័យថាមពល ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និងអគ្គិសនី ក្នុងតំបន់និងអន្តរជាតិ
- ជំរុញការវិនិយោគនិងការធ្វើពាណិជ្ជកម្មក្នុងវិស័យថាមពល
- គ្រប់គ្រងការអភិវឌ្ឍវិស័យថាមពល
- គ្រប់គ្រងកិច្ចការផ្នែកថាមពលវារីអគ្គិសនី
- គ្រប់គ្រងកិច្ចការផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មរួមមានកិច្ចការសុវត្ថិភាព ការការពារសុវត្ថិភាព និងសហការលើការងារសន្តិសុខបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មជាមួយស្ថាប័នពាក់ព័ន្ធ
- គ្រប់គ្រងកិច្ចការផ្នែកថាមពលកំដៅនិងចំហេះ
- គ្រប់គ្រងកិច្ចការផ្នែកថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត និង
- គ្រប់គ្រងបច្ចេកទេសនិងគោលនយោបាយអាជីវកម្មក្នុងវិស័យថាមពល។

ប្រការ៦ ..

អគ្គនាយកដ្ឋានថាមពលដឹកនាំដោយអគ្គនាយកមួយរូបនិងអមដោយអគ្គនាយករងមួយចំនួន អនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

ប្រការ៧ ..

អគ្គនាយកដ្ឋានថាមពលមាននាយកដ្ឋានក្រោមឱវាទចំនួន០៦(ប្រាំមួយ)ដូចខាងក្រោម៖

- នាយកដ្ឋានអភិវឌ្ឍថាមពល
- នាយកដ្ឋានវារីអគ្គិសនី
- នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូ
- នាយកដ្ឋានថាមពលកំដៅនិងចំហេះ
- នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត និង
- នាយកដ្ឋានបច្ចេកទេសនិងគោលនយោបាយអាជីវកម្មថាមពល។

ប្រការ៨ ..

នាយកដ្ឋាននីមួយៗនិងការិយាល័យចំណុះឱ្យនាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូបនិង អមដោយអនុប្រធានមួយចំនួនអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន។

អង្គការលេខរបស់អគ្គនាយកដ្ឋានថាមពលមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

ជំពូកទី៣
នាយកដ្ឋានអភិវឌ្ឍថាមពល

ប្រការ៩ ..

នាយកដ្ឋានអភិវឌ្ឍថាមពលចំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពលដោយមាន ភារកិច្ចដូចខាងក្រោម៖

- រៀបចំច្បាប់ គោលនយោបាយ និងយុទ្ធសាស្ត្រ អភិវឌ្ឍវិស័យថាមពល
- គ្រប់គ្រងប្រព័ន្ធទិន្នន័យនិងព័ត៌មានវិស័យថាមពល ព្យាករណ៍តម្រូវការថាមពល និងវិភាគអំពីតុល្យភាពរវាងប្រភពថាមពលដែលមាន និងតម្រូវការថាមពល
- រៀបចំការសិក្សានិងការអនុម័តផែនការមេដើម្បីធ្វើជាផែនទីបង្ហាញផ្លូវក្នុងការអភិវឌ្ឍវិស័យថាមពល
- រៀបចំផែនការនិងកម្មវិធីវិនិយោគដើម្បីអភិវឌ្ឍគម្រោងនានាក្នុងផែនការមេ
- ជំរុញការវិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគសម្រាប់គម្រោងអភិវឌ្ឍនីមួយៗ
- ត្រួតពិនិត្យការអនុវត្តគម្រោងអភិវឌ្ឍក្នុងដំណាក់កាលសាងសង់ និង
- ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការនិងការធ្វើពាណិជ្ជកម្មក្នុងតំបន់និងអន្តរជាតិ លើវិស័យ-ថាមពល។

ប្រការ១០ ..

នាយកដ្ឋានអភិវឌ្ឍថាមពលមានការិយាល័យក្រោមឱវាទចំនួន០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យស្ថិតិថាមពល
- ការិយាល័យគោលនយោបាយនិងផែនការអភិវឌ្ឍ
- ការិយាល័យនីតិវិធីវិនិយោគ និង
- ការិយាល័យត្រួតពិនិត្យការអភិវឌ្ឍគម្រោង។

ប្រការ១១ ..

ការិយាល័យស្ថិតិថាមពលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ប្រមូលនិងចងក្រងទិន្នន័យនិងព័ត៌មានគ្រប់ប្រភេទក្នុងវិស័យថាមពលទាំងទិន្នន័យហេដ្ឋារចនាសម្ព័ន្ធនិងទាំងទិន្នន័យថាមពលផលិត នាំចូល បញ្ជូន និងចែកចាយ
- សិក្សានិងវិភាគលើទិន្នន័យនិងព័ត៌មានទាំងនេះ៖ ព្យាករណ៍តម្រូវការ និងវិភាគអំពីតុល្យភាពរវាងប្រភពថាមពលដែលមាននិងតម្រូវការថាមពល
- រៀបចំរបាយការណ៍ស្ថិតិថាមពលដែលរួមមានស្ថានភាពហេដ្ឋារចនាសម្ព័ន្ធវិស័យថាមពល ស្ថានភាពថាមពល ផលិត នាំចូល បញ្ជូន និងចែកចាយ និងការវិភាគអំពីតុល្យភាពថាមពលប្រចាំឆ្នាំ
- រៀបចំបោះពុម្ពនិងផ្សព្វផ្សាយរបាយការណ៍ស្ថិតិថាមពលប្រចាំឆ្នាំ
- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ថែទាំ ជួសជុល បែងចែកនិងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន និង
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន។

ការិយាល័យគោលនយោបាយនិងផែនការអភិវឌ្ឍជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យថាមពល
- រៀបចំការសិក្សានិងការអនុម័តផែនការមេដើម្បីអភិវឌ្ឍវិស័យថាមពល

- រៀបចំផែនការនិងកម្មវិធីវិនិយោគគម្រោង ដែលរួមមានផែនការនិងកម្មវិធីវិនិយោគប្រភពផ្គត់-ផ្គង់ ផែនការ និងកម្មវិធីវិនិយោគប្រព័ន្ធបញ្ជូន ផែនការនិងកម្មវិធីវិនិយោគប្រព័ន្ធចែកចាយ និង ផែនការនិងកម្មវិធី វិនិយោគ ពង្រីកអគ្គិសនីភាវូបនីយកម្មជនបទ ដោយសហការពិគ្រោះយោបល់ជាមួយនាយកដ្ឋានទទួលបន្ទុកនីមួយៗ
- ពិភាក្សាជាមួយភាគីពាក់ព័ន្ធដើម្បីកំណត់ប្រភេទនៃការវិនិយោគគម្រោងនីមួយៗ ជាការវិនិយោគរបស់រដ្ឋ វិនិយោគរបស់ឯកជន ឬជាការវិនិយោគចំរុះរវាងរដ្ឋនិងឯកជន។ល។ និងរកលទ្ធភាពធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងនីមួយៗ
- វាយតម្លៃលើសំណើសុំគោលការណ៍អនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍនីមួយៗរបស់អ្នកមានចំណេងវិនិយោគដោយសហការពិគ្រោះយោបល់ជាមួយនាយកដ្ឋានទទួលបន្ទុក និង
- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងវិស័យថាមពល។

ការិយាល័យនីតិវិធីវិនិយោគជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ប្រមូលផ្តុំឯកសារច្បាប់ គោលនយោបាយ គោលការណ៍ និងបទប្បញ្ញត្តិទាក់ទងនឹងការជ្រើសរើសអ្នកវិនិយោគគម្រោងនិងការសម្រេចឱ្យវិនិយោគ
- ទាក់ទាញវិនិយោគិនឱ្យចូលរួមវិនិយោគ សិក្សា និងផ្តល់យោបល់លើនីតិវិធីនៃការជ្រើសរើសអ្នកវិនិយោគគម្រោងនីមួយៗដោយអនុវត្តនីតិវិធីដេញថ្លៃឬនីតិវិធីផ្សេងទៀតទៅតាមស្ថានភាពជាក់ស្តែងនៃការអភិវឌ្ឍគម្រោង
- រៀបចំការដេញថ្លៃជ្រើសរើសអ្នកវិនិយោគគម្រោងប្រសិនបើគម្រោងត្រូវអនុវត្តតាមនីតិវិធីដេញថ្លៃ
- រៀបចំការជ្រើសរើសអ្នកវិនិយោគគម្រោងតាមនីតិវិធីផ្សេងទៀតប្រសិនបើគម្រោងនោះត្រូវអនុវត្តតាមនីតិវិធីផ្សេងក្រៅពីដេញថ្លៃ និង
- រៀបចំការចរចាកិច្ចព្រមព្រៀងវិនិយោគ រៀបចំរបាយការណ៍អំពីការចរចា និងរៀបចំឯកសារសុំការសម្រេចនិងអនុម័តឱ្យវិនិយោគគម្រោង។

ការិយាល័យត្រួតពិនិត្យការអភិវឌ្ឍគម្រោងជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សិក្សាអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀង លក្ខណៈបច្ចេកទេសនៃហេដ្ឋារចនាសម្ព័ន្ធ កម្មវិធីសាងសង់នៃគម្រោងវិនិយោគនីមួយៗ
- ដឹកនាំការពិភាក្សាជាមួយនឹងនាយកដ្ឋានទទួលបន្ទុកនិងភាគីពាក់ព័ន្ធ ដើម្បីពិនិត្យការស្នើសុំកែសម្រួលលក្ខខណ្ឌកិច្ចព្រមព្រៀង លក្ខណៈបច្ចេកទេស កម្មវិធីសាងសង់នៃគម្រោង និងការស្នើសុំរួចពន្ធរបស់គម្រោង
- សម្របសម្រួល ដោះស្រាយបញ្ហាដែលកើតឡើងក្នុងដំណាក់កាលសាងសង់នៃការអនុវត្តគម្រោង

- អនុវត្តកិច្ចការត្រួតពិនិត្យគម្រោងក្នុងកូនាទីជាវិស្វករគម្រោងដោយសហការជាមួយនាយកដ្ឋានទទួលបន្ទុក និង
- ចូលរួមពិនិត្យ ធ្វើតេស្ត និងដាក់ឱ្យដំណើរការគម្រោងដោយសហការជាមួយនាយកដ្ឋានទទួលបន្ទុក។

ជំពូកទី៤
នាយកដ្ឋានវារីអគ្គិសនី

ប្រការ១២ ..

នាយកដ្ឋានវារីអគ្គិសនីបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពលដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យថាមពល ពាក់ព័ន្ធជាមួយនឹងផ្នែកវារីអគ្គិសនី
- ស្រាវជ្រាវនិងតាមដានការវិវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្តង់ដារផ្នែកវារីអគ្គិសនី
- ប្រមូលផ្តុំនិងចងក្រងទិន្នន័យនិងព័ត៌មានផ្នែកវារីអគ្គិសនី រៀបចំស្ថិតិសក្តានុពលប្រភពវារីអគ្គិសនីនិងកំណត់គម្រោងអាទិភាពផ្នែកវារីអគ្គិសនីដែលអាចបញ្ចូលក្នុងផែនការមេដើម្បីធ្វើការអភិវឌ្ឍ
- ចូលរួមផ្តល់យោបល់ក្នុងការរៀបចំផែនការមេនិងចូលរួមរៀបចំផែនការនិងកម្មវិធីវិនិយោគប្រភពថាមពល
- ចូលរួមក្នុងការងារជំរុញការវិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគសម្រាប់គម្រោងអភិវឌ្ឍផ្នែកវារីអគ្គិសនី
- ចូលរួមក្នុងការត្រួតពិនិត្យការសាងសង់និងការប្រគល់ទទួលនៃគម្រោងផ្នែកវារីអគ្គិសនី
- ត្រួតពិនិត្យនិងតាមដានការអនុវត្តគម្រោងវារីអគ្គិសនីក្នុងដំណាក់កាលនៃការដំណើរការ
- ចូលរួមសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងវារីអគ្គិសនីនិងការរៀបចំផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គម និង
- ត្រួតពិនិត្យតាមដានការអនុវត្តផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងវារីអគ្គិសនីទាំងក្នុងដំណាក់កាលសាងសង់និងទាំងក្នុងដំណាក់កាលដំណើរការ។

ប្រការ១៣ ..

នាយកដ្ឋានវារីអគ្គិសនីមានការិយាល័យក្រោមឱវាទចំនួន០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាវារីអគ្គិសនី
- ការិយាល័យផែនការនិងអភិវឌ្ឍគម្រោងវារីអគ្គិសនី
- ការិយាល័យត្រួតពិនិត្យដំណើរការស្ថានីយវារីអគ្គិសនី និង
- ការិយាល័យគ្រប់គ្រងផែនការកាត់បន្ថយផលប៉ះពាល់នៃគម្រោងវារីអគ្គិសនី

ប្រការ១៤ ..

ការិយាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាវារីអគ្គិសនីជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវនិងតាមដានការវិវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវារីអគ្គិសនី
- គ្រប់គ្រងបន្ទប់ពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាវារីអគ្គិសនី
- រៀបចំនិងកំណត់ស្តង់ដារពាក់ព័ន្ធវារីអគ្គិសនី
- ចូលរួមក្នុងកិច្ចការនានារបស់នាយកដ្ឋានដែលពាក់ព័ន្ធជាមួយនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាវារីអគ្គិសនី
- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធជាមួយនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃផ្នែកវារីអគ្គិសនី
- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ផ្គត់ផ្គង់ ថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ហីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន និង
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន។

ការិយាល័យផែនការនិងអភិវឌ្ឍគម្រោងវារីអគ្គិសនីជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យថាមពលដោយផ្តល់យោបល់ផ្នែកវារីអគ្គិសនី
- ប្រមូលផ្តុំព័ត៌មាននិងទិន្នន័យ រៀបចំស្ថិតិសក្តានុពលប្រភពថាមពលវារីអគ្គិសនី និងគម្រោងពហុបំណង
- ចូលរួមផ្តល់យោបល់ក្នុងការសិក្សានិងការអនុម័តផែនការមេដើម្បីអភិវឌ្ឍវិស័យថាមពល
- ចូលរួមរៀបចំផែនការនិងកម្មវិធីវិនិយោគគម្រោងពាក់ព័ន្ធជាមួយនឹងវារីអគ្គិសនី
- ចូលរួមជំរុញវិនិយោគិនឱ្យចូលរួមវិនិយោគ ត្រួតពិនិត្យ និងវាយតម្លៃលើសំណើសុំគោលការណ៍អនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍផ្នែកវារីអគ្គិសនី

- ចូលរួមជាមួយនាយកដ្ឋានអភិវឌ្ឍថាមពលក្នុងការងាររៀបចំជ្រើសរើសអ្នកវិនិយោគ ការងារ រៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគ ការងារត្រួតពិនិត្យការសាងសង់ និងការប្រគល់ទទួល នៃគម្រោងអភិវឌ្ឍផ្នែកវារីអគ្គិសនី និង
- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងផ្នែកវារីអគ្គិសនី

ការិយាល័យត្រួតពិនិត្យដំណើរការស្ថានីយវារីអគ្គិសនីជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋាន ដោយមានភារកិច្ចដូចខាងក្រោម៖

- សិក្សាអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងវិនិយោគ លក្ខណៈបច្ចេកទេសនៃហេដ្ឋារចនាសម្ព័ន្ធ លក្ខខណ្ឌដំណើរការនៃស្ថានីយវារីអគ្គិសនីរបស់គម្រោងនីមួយៗ
- ចូលរួមត្រួតពិនិត្យការធ្វើតេស្តនិងការដាក់ឱ្យដំណើរការគម្រោងវារីអគ្គិសនី
- គ្រប់គ្រង តាមដាន ព័ត៌មាន ទិន្នន័យ ប្រសិទ្ធភាព និងលក្ខណៈបច្ចេកទេសនៃការដំណើរការ ស្ថានីយវារីអគ្គិសនីនិងស្ថានីយវារីក្នុងគម្រោងពហុបំណងដែលបានអភិវឌ្ឍរួច និង
- ត្រួតពិនិត្យ តាមដាន ស្ថានភាព សុវត្ថិភាព នៃហេដ្ឋារចនាសម្ព័ន្ធស្ថានីយវារីអគ្គិសនីនិងស្ថានីយ វារីក្នុងគម្រោងពហុបំណងដែលបានអភិវឌ្ឍរួច។

ការិយាល័យគ្រប់គ្រងផែនការកាត់បន្ថយផលប៉ះពាល់នៃគម្រោងវារីអគ្គិសនីជាសេនាធិការឱ្យថ្នាក់ ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងវារីអគ្គិសនី
- ចូលរួមរៀបចំផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងវារីអគ្គិសនី
- តំណាងឱ្យនាយកដ្ឋានវារីអគ្គិសនីក្នុងការពន្យល់បំភ្លឺពាក់ព័ន្ធជាមួយបញ្ហាបរិស្ថាននិងសង្គម របស់គម្រោងវារីអគ្គិសនី និង
- ត្រួតពិនិត្យតាមដានការអនុវត្តផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គម ទាំងក្នុងពេល សាងសង់និងទាំងក្រោយពេលដាក់ឱ្យដំណើរការរបស់គម្រោងវារីអគ្គិសនី។

ជំពូកទី៥
នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូ

ប្រការ១៥ ..

នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋាន ថាមពលដោយមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំនិងកំណត់គោលនយោបាយ យុទ្ធសាស្ត្រ ច្បាប់ បទប្បញ្ញត្តិ ស្តង់ដារ និងសេចក្តីណែនាំ ក្នុងផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម
- ចូលរួមសិក្សានិងរៀបចំផែនការអភិវឌ្ឍវិស័យថាមពលពាក់ព័ន្ធនឹងផ្នែកថាមពលបរមាណូ
- ស្រាវជ្រាវនិងអភិវឌ្ឍវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម

- ជំរុញការវិនិយោគនិងចូលរួមអនុវត្តគម្រោងទាក់ទងនឹងការប្រើប្រាស់បច្ចេកវិទ្យាបរមាណូស៊ីវិល សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព
- រៀបចំនិងកំណត់ស្តង់ដារសម្រាប់ការពារបុគ្គល សាធារណៈជន និងបរិស្ថាន ឱ្យចៀសផុតពីលទ្ធភាពរងផលប៉ះពាល់អាក្រក់ពីវិទ្យុសកម្ម
- អនុវត្តមុខងារបញ្ជាតុករគ្រប់គ្រង ការផ្តល់ កែសម្រួល ព្យួរ ឬដកហូតអាជ្ញាបណ្ណ ការយកកម្រៃអាជ្ញាបណ្ណ និងត្រួតពិនិត្យការផ្តល់សេវាទាំងឡាយដែលពាក់ព័ន្ធនឹងផ្នែកបរមាណូស៊ីវិលនិងវិទ្យុសកម្ម
- ធ្វើអធិការកិច្ចនិងចាត់វិធានការឱ្យអនុវត្ត អនុលោមទៅតាមសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង បទប្បញ្ញត្តិ ស្តង់ដារ និងអាជ្ញាបណ្ណចំពោះសកម្មភាពនិងហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មក្នុងគោលបំណងរក្សាសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិភាព និងអនុវត្តកិច្ចការដទៃទៀតដែលចាំបាច់សម្រាប់ការពារប្រជាជននិងបរិស្ថាន ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចៀសផុតពីគ្រោះថ្នាក់បរមាណូស៊ីវិលនិងវិទ្យុសកម្ម
- គ្រប់គ្រងសន្និធិប្រភពវិទ្យុសកម្មជាតិ និង
- ធ្វើសហប្រតិបត្តិការជាមួយនឹងស្ថាប័នជាតិនិងអន្តរជាតិ និងប្រទេសដទៃទៀតពាក់ព័ន្ធនឹងការងារសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិភាពផ្នែកបរមាណូស៊ីវិលនិងវិទ្យុសកម្ម។

ប្រការ១៦ ..

នាយកដ្ឋានវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាបរមាណូមានការិយាល័យក្រោមឱវាទចំនួន០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍ
- ការិយាល័យអាជ្ញាបណ្ណនិងបទប្បញ្ញត្តិ
- ការិយាល័យសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិភាព និង
- ការិយាល័យគោលនយោបាយ ផែនការ និងគម្រោង។

ប្រការ១៧ ..

ការិយាល័យស្រាវជ្រាវនិងអភិវឌ្ឍជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម
- រៀបចំនិងកំណត់ស្តង់ដារបច្ចេកទេសក្នុងផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម
- គ្រប់គ្រងបន្ទប់ពិសោធន៍និងបរិធានផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម និង
- ពិនិត្យលទ្ធភាពនិងជំរុញការអភិវឌ្ឍនានាដែលប្រើប្រាស់បច្ចេកវិទ្យាផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្មក្នុងប្រទេសកម្ពុជា។

ការិយាល័យអាជ្ញាបណ្ណនិងបទប្បញ្ញត្តិជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រងការផ្តល់ កែសម្រួល ព្យួរ ឬដកហូតអាជ្ញាបណ្ណ និងការយកកម្រៃអាជ្ញាបណ្ណលើការផ្តល់សេវាទាក់ទងជាមួយនឹងផ្នែកបរមាណូស៊ីវិលនិងវិទ្យុសកម្មជាជំហានដំបូងក្នុងផ្នែកកាំរស្មីអ៊ិច ផ្នែកបាញ់កាំរស្មី ផ្នែកវេជ្ជសាស្ត្របរមាណូ ផ្នែកអ៊ីសូតូប និងផ្នែកអាហារ័ណនីហរ័ណ និង
- រៀបចំនិងកំណត់លក្ខខណ្ឌអាជ្ញាបណ្ណនិងបទប្បញ្ញត្តិ ព្រមទាំងចុះតាមដានត្រួតពិនិត្យលើការផ្តល់សេវាទាក់ទងជាមួយនឹងផ្នែកបរមាណូស៊ីវិលនិងវិទ្យុសកម្មជាជំហានដំបូងក្នុងផ្នែកកាំរស្មីអ៊ិច ផ្នែកបាញ់កាំរស្មី ផ្នែកវេជ្ជសាស្ត្របរមាណូ ផ្នែកអ៊ីសូតូប និងផ្នែកអាហារ័ណនីហរ័ណ ។

ការិយាល័យសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិភាពជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងកំណត់ស្តង់ដារនិងបទប្បញ្ញត្តិពាក់ព័ន្ធនឹងសុវត្ថិភាព សន្តិសុខ និងការការពារសុវត្ថិ-ភាពក្នុងផ្នែកបរមាណូស៊ីវិលនិងវិទ្យុសកម្ម
- ធ្វើអធិការកិច្ចនិងចាត់វិធានការឱ្យអនុវត្ត អនុលោមទៅតាមបទប្បញ្ញត្តិ ស្តង់ដារ និងអាជ្ញាបណ្ណ ចំពោះសកម្មភាពនិងហេដ្ឋារចនាសម្ព័ន្ធទាក់ទងនឹងផ្នែកបរមាណូស៊ីវិលនិងវិទ្យុសកម្ម ក្នុងគោលបំណង រក្សាសុវត្ថិភាព សន្តិសុខ (ដោយសហការជាមួយនឹងស្ថាប័នជំនាញ) និងការការពារសុវត្ថិភាព
- អនុវត្តកិច្ចការដទៃទៀតដែលចាំបាច់សម្រាប់ការពារប្រជាជននិងបរិស្ថានក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចៀសផុតពីគ្រោះថ្នាក់បរមាណូស៊ីវិលនិងវិទ្យុសកម្ម និង
- សហការជាមួយនឹងស្ថាប័នជាតិ/អន្តរជាតិ និងប្រទេសដទៃទៀតពាក់ព័ន្ធការងារសុវត្ថិភាព សន្តិ-សុខ និងការការពារសុវត្ថិភាពផ្នែកបរមាណូស៊ីវិលនិងវិទ្យុសកម្ម។

ការិយាល័យគោលនយោបាយ ផែនការ និងគម្រោងជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ជួយរៀបចំនិងកំណត់គោលនយោបាយ យុទ្ធសាស្ត្រ ក្នុងផ្នែកបរមាណូស៊ីវិលរួមទាំងវិទ្យុសកម្ម
- រៀបចំផែនការគម្រោងជាមួយនឹងស្ថាប័នបរមាណូអន្តរជាតិឬប្រទេសផ្សេងទៀត
- សហការអនុវត្តគម្រោងជាមួយនឹងស្ថាប័នបរមាណូអន្តរជាតិឬប្រទេសផ្សេងទៀត
- ចូលរួមរៀបចំផែនការអភិវឌ្ឍវិស័យថាមពលនិងផ្តល់យោបល់ផ្នែកថាមពលបរមាណូស៊ីវិល
- ចូលរួមអនុវត្តគម្រោងពាក់ព័ន្ធជាមួយថាមពលបរមាណូស៊ីវិល
- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន

- គ្រប់គ្រង ថែទាំ ជួសជុល បែងចែកនិងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន និង
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន។

ជំពូកទី៦
នាយកដ្ឋានថាមពលកំដៅនិងចំហេះ

ប្រការ១៨ ..

នាយកដ្ឋានថាមពលកំដៅនិងចំហេះបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពលដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យថាមពលពាក់ព័ន្ធជាមួយនឹងផ្នែកថាមពលកំដៅនិងចំហេះ
- ស្រាវជ្រាវនិងតាមដានការវិវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្តង់ដារផ្នែកថាមពលកំដៅនិងចំហេះ
- ប្រមូលផ្តុំនិងចងក្រងទិន្នន័យនិងព័ត៌មានផ្នែកថាមពលកំដៅនិងចំហេះ រៀបចំស្ថិតិសក្តានុពលប្រភពថាមពលកំដៅនិងចំហេះ និងកំណត់គម្រោងអាទិភាពផ្នែកថាមពលកំដៅនិងចំហេះដែលអាចបញ្ចូលក្នុងផែនការមេដើម្បីធ្វើការអភិវឌ្ឍ
- ចូលរួមផ្តល់យោបល់ក្នុងការរៀបចំផែនការមេនិងចូលរួមរៀបចំផែនការនិងកម្មវិធីវិនិយោគប្រភពថាមពល
- ចូលរួមជំរុញការវិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគសម្រាប់គម្រោងអភិវឌ្ឍផ្នែកថាមពលកំដៅនិងចំហេះ
- ចូលរួមត្រួតពិនិត្យការសិក្សា ការសាងសង់ និងការប្រគល់ទទួលគម្រោងប្រភពថាមពលកំដៅនិងចំហេះ
- ត្រួតពិនិត្យតាមដានការអនុវត្តគម្រោងប្រភពថាមពលកំដៅនិងចំហេះក្នុងដំណាក់កាលនៃការដំណើរការ
- ចូលរួមសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងប្រភពថាមពលកំដៅនិងចំហេះ និងការរៀបចំផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គម និង
- ត្រួតពិនិត្យតាមដានការអនុវត្តផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គម របស់គម្រោងប្រភពថាមពលកំដៅនិងចំហេះទាំងក្នុងដំណាក់កាលសាងសង់និងទាំងក្នុងដំណាក់កាលដំណើរការ។

ប្រការ១៩ ..

នាយកដ្ឋានថាមពលកំដៅនិងចំហេះមានការិយាល័យក្រោមឱវាទចំនួន០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកំដៅនិងចំហេះ
- ការិយាល័យផែនការនិងអភិវឌ្ឍគម្រោងថាមពលកំដៅនិងចំហេះ

- ការិយាល័យត្រួតពិនិត្យដំណើរការស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហេះ និង
- ការិយាល័យគ្រប់គ្រងផែនការកាត់បន្ថយផលប៉ះពាល់នៃស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហេះ

ប្រការ២០ ..

ការិយាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកំដៅនិងចំហេះជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ការងារស្រាវជ្រាវវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកំដៅនិងចំហេះ
- គ្រប់គ្រងបន្ទប់ពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាថាមពលកំដៅនិងចំហេះ
- តាមដានការរីកចម្រើននិងការវិវត្តនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកំដៅនិងចំហេះ
- រៀបចំនិងកំណត់ស្តង់ដារពាក់ព័ន្ធនឹងថាមពលកំដៅនិងចំហេះ
- វិភាគនិងជ្រើសរើសប្រភេទឡចំហាយ ម៉ាស៊ីនចំហេះ និងឡឧស្ម័នដែលកម្ពុជាគួរប្រើប្រាស់ក្នុងការអភិវឌ្ឍ
- ចូលរួមក្នុងកិច្ចការនានារបស់នាយកដ្ឋានពាក់ព័ន្ធជាមួយនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកំដៅនិងចំហេះ
- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធជាមួយនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃថាមពលកំដៅនិងចំហេះ
- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ថែទាំជួសជុល បែងចែកនិងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន និង
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន។

ការិយាល័យផែនការនិងអភិវឌ្ឍគម្រោងថាមពលកំដៅនិងចំហេះជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យថាមពលដោយផ្តល់យោបល់ផ្នែកថាមពលកំដៅនិងចំហេះ
- ប្រមូលផ្តុំព័ត៌មាននិងទិន្នន័យរៀបចំស្ថិតិសក្តានុពលប្រភពថាមពលថាមពលកំដៅនិងចំហេះ

- ចូលរួមផ្តល់យោបល់ក្នុងការសិក្សានិងការអនុម័តផែនការមេដើម្បីអភិវឌ្ឍវិស័យថាមពល
- ចូលរួមរៀបចំផែនការនិងកម្មវិធីវិនិយោគគម្រោងពាក់ព័ន្ធជាមួយនឹងផ្នែកថាមពលកំដៅនិងចំហៀ:
- ចូលរួមជំរុញវិនិយោគិនឱ្យចូលរួមវិនិយោគ ត្រួតពិនិត្យ និងវាយតម្លៃលើសំណើសុំគោលការណ៍អនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍផ្នែកថាមពលកំដៅនិងចំហៀ:
- ចូលរួមជាមួយនាយកដ្ឋានអភិវឌ្ឍថាមពលក្នុងការងាររៀបចំជ្រើសរើសអ្នកវិនិយោគ ការងាររៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគ ការងារត្រួតពិនិត្យការសាងសង់ និងការប្រគល់ទទួលនៃគម្រោងអភិវឌ្ឍផ្នែកថាមពលកំដៅនិងចំហៀ: និង
- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងផ្នែកថាមពលកំដៅនិងចំហៀ:។

ការិយាល័យត្រួតពិនិត្យដំណើរការស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម:

- សិក្សាអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងវិនិយោគ លក្ខណៈបច្ចេកទេសនៃហេដ្ឋារចនាសម្ព័ន្ធ លក្ខខណ្ឌដំណើរការនៃស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:របស់គម្រោងនីមួយៗ
- ចូលរួមត្រួតពិនិត្យការធ្វើតេស្តនិងការដាក់ឱ្យដំណើរការគម្រោងស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:
- គ្រប់គ្រង តាមដាន ព័ត៌មាន ទិន្នន័យ ប្រសិទ្ធភាព និងលក្ខណៈបច្ចេកទេសនៃការដំណើរការស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:ដែលបានអភិវឌ្ឍរួច
- ចូលរួមវិភាគគុណភាពវត្ថុធាតុដើមនៃស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:ដែលបានអភិវឌ្ឍរួច និង
- ត្រួតពិនិត្យ តាមដាន ស្ថានភាព សុវត្ថិភាពនៃស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:ដែលបានអភិវឌ្ឍរួច។

ការិយាល័យគ្រប់គ្រងផែនការកាត់បន្ថយផលប៉ះពាល់នៃស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ: ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម:

- ចូលរួមសិក្សាវាយតម្លៃផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:
- ចូលរួមរៀបចំផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:
- តំណាងឱ្យនាយកដ្ឋានថាមពលកំដៅនិងចំហៀ:ក្នុងការពន្យល់បំភ្លឺពាក់ព័ន្ធជាមួយនឹងបញ្ហាបរិស្ថាននិងសង្គមរបស់គម្រោងស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ:
- ត្រួតពិនិត្យនិងតាមដានការប៉ះពាល់បរិស្ថានដោយការដឹកជញ្ជូននិងការប្រើប្រាស់វត្ថុធាតុដើមនៃស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហៀ: និង

- ត្រួតពិនិត្យតាមដានការអនុវត្តផែនការកាត់បន្ថយផលប៉ះពាល់បរិស្ថាននិងសង្គមទាំងក្នុងពេលសាងសង់និងទាំងក្រោយពេលដាក់ឱ្យដំណើរការរបស់គម្រោងស្ថានីយអគ្គិសនីដើរដោយកំដៅនិងចំហេះ។

ជំពូកទី៧
នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត

ប្រការ២១ ..

នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពលដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ ពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍនិងការប្រើប្រាស់ថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- ស្រាវជ្រាវនិងតាមដានការវិវត្តវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្តង់ដារនៃថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- រៀបចំការសិក្សាអំពីសក្តានុពលនៃថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត ដែលអាចមាននៅកម្ពុជាសម្រាប់ការប្រើប្រាស់គ្រប់ប្រភេទដែលមានប្រយោជន៍
- ប្រមូលផ្តុំចងក្រងទិន្នន័យនិងព័ត៌មាន រៀបចំស្ថិតិសក្តានុពលនៃថាមពលទាំងនេះដែលអាចអភិវឌ្ឍភ្ជាប់បញ្ចូលក្នុងប្រព័ន្ធបណ្តាញជាតិឬអាចអភិវឌ្ឍសម្រាប់ការប្រើប្រាស់ដោយឡែក
- ផ្តល់យោបល់អំពីការបញ្ចូលការអភិវឌ្ឍប្រភពថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតទៅក្នុងផែនការរមេ ចូលរួមរៀបចំផែនការរមេ និងចូលរួមរៀបចំផែនការនិងកម្មវិធីវិនិយោគប្រភពថាមពល
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍថាមពលក្នុងការជំរុញការវិនិយោគ រៀបចំជ្រើសរើសអ្នកវិនិយោគ ត្រួតពិនិត្យការសាងសង់ និងការប្រគល់ទទួលសម្រាប់គម្រោងអភិវឌ្ឍផ្នែកថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- ត្រួតពិនិត្យនិងតាមដានការដំណើរការស្ថានីយអគ្គិសនីដើរដោយថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតបន្ទាប់ពីអភិវឌ្ឍរួច និង
- សិក្សាវាយតម្លៃផលប្រយោជន៍និងផលប៉ះពាល់នៃការប្រើប្រាស់ថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត ធ្វើការផ្សព្វផ្សាយនិងសហប្រតិបត្តិការ ដើម្បីជំរុញការអភិវឌ្ឍនិងការប្រើប្រាស់ថាមពលនេះ។

ប្រការ២២ ..

នាយកដ្ឋានថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតមានការិយាល័យក្រោមឱវាទចំនួន០៤ (បួន)ដូចខាងក្រោម៖

ការិយាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត

- ការិយាល័យផែនការនិងអភិវឌ្ឍគម្រោងថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- ការិយាល័យត្រួតពិនិត្យដំណើរការស្ថានីយថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត និង
- ការិយាល័យជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត។

ប្រការ២៣ ..

ការិយាល័យវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ការងារស្រាវជ្រាវនិងតាមដានការវិវត្តនៃវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត
- គ្រប់គ្រងបន្ទប់ពិសោធន៍ពាក់ព័ន្ធនឹងបច្ចេកវិទ្យាថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- រៀបចំនិងកំណត់ស្តង់ដារពាក់ព័ន្ធនឹងថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- វិភាគនិងជ្រើសរើសបច្ចេកវិទ្យានិងបរិក្ខារថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតដែលកម្ពុជាគួរអភិវឌ្ឍ
- ចូលរួមក្នុងកិច្ចការនានាពាក់ព័ន្ធជាមួយវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត និង
- ផ្សព្វផ្សាយនិងចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធជាមួយនឹងវិទ្យាសាស្ត្របច្ចេកវិទ្យា និងស្តង់ដារនៃថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត។

ការិយាល័យផែនការនិងអភិវឌ្ឍគម្រោងថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យថាមពលដោយផ្តល់យោបល់លើផ្នែកថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- ប្រមូលផ្តុំព័ត៌មាននិងទិន្នន័យ រៀបចំស្ថិតិសក្តានុពលប្រភពថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត និងចូលរួមផ្តល់យោបល់ក្នុងការបញ្ចូលថាមពលទាំងនេះទៅក្នុងផែនការមេ
- ចូលរួមរៀបចំផែនការនិងកម្មវិធីវិនិយោគគម្រោងពាក់ព័ន្ធជាមួយនឹងថាមពលកកើតឡើងវិញ និងថាមពលផ្សេងទៀត
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍថាមពល ជំរុញការវិនិយោគ ត្រួតពិនិត្យនិងវាយតម្លៃជ្រើសរើសអ្នកវិនិយោគ ការសាងសង់ និងការប្រគល់ទទួលគម្រោងវិនិយោគផ្នែកថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត និង
- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការក្នុងផ្នែកថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត។

ការិយាល័យត្រួតពិនិត្យដំណើរការស្ថានីយថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សិក្សាអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងវិនិយោគ លក្ខណៈបច្ចេទេស និងលក្ខខណ្ឌដំណើរការនៃគម្រោង

- ចូលរួមត្រួតពិនិត្យការធ្វើតេស្តនិងការដាក់ឱ្យដំណើរការគម្រោងថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- គ្រប់គ្រង តាមដាន ព័ត៌មាន ទិន្នន័យ ប្រសិទ្ធភាព និងលក្ខណៈបច្ចេកទេសនៃការដំណើរការគម្រោងផ្នែកថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតដែលបានអភិវឌ្ឍរួច និង
- ត្រួតពិនិត្យ តាមដាន ប្រសិទ្ធភាពនៃគម្រោងថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតដែលបានអភិវឌ្ឍរួច។

ការិយាល័យជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀតជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- សិក្សាវាយតម្លៃអំពីផលប្រយោជន៍នៃការប្រើប្រាស់ថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- ទំនាក់ទំនងនិងទាក់ទាញប្រភពថវិកានានាដើម្បីអនុវត្តកម្មវិធីប្រើប្រាស់ថាមពលកកើតឡើងវិញនៅតំបន់ដែលប្រភពបណ្តាញជាតិពុំទាន់អភិវឌ្ឍទៅដល់
- ធ្វើការផ្សព្វផ្សាយនិងធ្វើសហប្រតិបត្តិការដើម្បីស្វែងរកការគាំទ្រនិងជំរុញការអភិវឌ្ឍនិងការប្រើប្រាស់ថាមពលកកើតឡើងវិញនិងថាមពលផ្សេងទៀត
- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ថែទាំ បែងចែកនិងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ហាវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន និង
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន។

ជំពូកទី៨
នាយកដ្ឋានបច្ចេកទេសនិងគោលនយោបាយអាជីវកម្មថាមពល

ប្រការ២៤.-

នាយកដ្ឋានបច្ចេកទេសនិងគោលនយោបាយអាជីវកម្មថាមពលបំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថាមពលដោយមានភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យថាមពល ពាក់ព័ន្ធជាមួយនឹងការបញ្ជូន ការចែកចាយ និងការធ្វើអាជីវកម្មថាមពល
- ស្រាវជ្រាវនិងតាមដានការវិវត្តនៃបច្ចេកវិទ្យានិងស្តង់ដារនៃការបញ្ជូននិងចែកចាយថាមពល
- រៀបចំនិងត្រួតពិនិត្យការអនុវត្តស្តង់ដារបច្ចេកទេសនិងស្តង់ដារសុវត្ថិភាពក្នុងការបញ្ជូន និងចែកចាយអគ្គិសនី និងការតបណ្តាញអគ្គិសនីក្នុងអគារនិងលំនៅដ្ឋាន
- ប្រមូលផ្តុំនិងចងក្រងទិន្នន័យនិងព័ត៌មាននៃការបញ្ជូន ការចែកចាយ និងការធ្វើអាជីវកម្មថាមពល រៀបចំសេចក្តីត្រូវការហេដ្ឋារចនាសម្ព័ន្ធបញ្ជូននិងចែកចាយដែលត្រូវបញ្ចូលក្នុងផែនការមេដើម្បីធ្វើការអភិវឌ្ឍ
- ចូលរួមផ្តល់យោបល់ក្នុងការរៀបចំផែនការមេ និងផែនការនិងកម្មវិធីវិនិយោគប្រព័ន្ធបញ្ជូននិងចែកចាយ
- ចូលរួមជំរុញការវិនិយោគគម្រោង រៀបចំកិច្ចការជ្រើសរើសអ្នកវិនិយោគ និងរៀបចំគោលការណ៍អនុញ្ញាតឱ្យវិនិយោគសម្រាប់គម្រោងអភិវឌ្ឍផ្នែកបញ្ជូននិងចែកចាយអគ្គិសនី
- ចូលរួមត្រួតពិនិត្យការសិក្សា ការសាងសង់ និងការប្រគល់ទទួលគម្រោងអភិវឌ្ឍផ្នែកបញ្ជូននិងចែកចាយ
- រៀបចំកំណត់គោលនយោបាយនិងសេចក្តីសម្រេចនានាពាក់ព័ន្ធជាមួយអាជីវកម្មនិងការផ្តល់សេវាផ្គត់ផ្គង់
- ត្រួតពិនិត្យ តាមដានការអនុវត្តគោលនយោបាយ និងសេចក្តីសម្រេចពាក់ព័ន្ធជាមួយនឹងអាជីវកម្ម និងការផ្តល់សេវាផ្គត់ផ្គង់ និង
- រៀបចំនិងត្រួតពិនិត្យការអនុវត្តគោលនយោបាយនិងយន្តការសន្សំសំចៃថាមពលនិងប្រសិទ្ធភាពថាមពល។

ប្រការ២៥ ..

នាយកដ្ឋានបច្ចេកទេសនិងគោលនយោបាយអាជីវកម្មថាមពលមានការិយាល័យក្រោមឱវាទចំនួន ០៤(បួន)ដូចខាងក្រោម៖

- ការិយាល័យស្តង់ដារ បច្ចេកទេសបណ្តាញផ្គត់ផ្គង់ និងបណ្តាញក្នុងអគារ
- ការិយាល័យផែនការនិងអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់
- ការិយាល័យគោលនយោបាយអាជីវកម្មផ្គត់ផ្គង់ និង
- ការិយាល័យការងារប្រសិទ្ធភាពនិងសន្សំសំចៃថាមពល។

ប្រការ២៦ ..

ការិយាល័យស្តង់ដារ បច្ចេកទេសបណ្តាញផ្គត់ផ្គង់ និងបណ្តាញក្នុងអគារជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ស្រាវជ្រាវនិងតាមដានការវិវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងស្តង់ដារនៃការបញ្ជូន និងចែកចាយអគ្គិសនីព្រមទាំងការតបណ្តាញក្នុងអគារនិងលំនៅដ្ឋាន
- រៀបចំនិងត្រួតពិនិត្យការអនុវត្តស្តង់ដារបច្ចេកទេសនិងស្តង់ដារសុវត្ថិភាពក្នុងការបញ្ជូន និងចែកចាយអគ្គិសនីព្រមទាំងការតបណ្តាញក្នុងអគារនិងលំនៅដ្ឋាន

- រៀបចំបទប្បញ្ញត្តិគ្រប់គ្រងការសាងសង់និងការតម្លើងហេដ្ឋារចនាសម្ព័ន្ធបញ្ជូននិងចែកចាយអគ្គិសនី ព្រមទាំងការតបណ្តាញក្នុងអគារនិងលំនៅដ្ឋាន
- រៀបចំលិខិតអនុញ្ញាតសម្រាប់នីតិបុគ្គលឬរូបវន្តបុគ្គលក្នុងការចូលរួមសាងសង់និងតម្លើងហេដ្ឋារចនាសម្ព័ន្ធបញ្ជូននិងចែកចាយអគ្គិសនីព្រមទាំងការតបណ្តាញក្នុងអគារនិងលំនៅដ្ឋាន
- បោះពុម្ពនិងផ្សព្វផ្សាយស្តង់ដារបច្ចេកទេស និងស្តង់ដារសុវត្ថិភាពក្នុងការបញ្ជូន និងចែកចាយអគ្គិសនីព្រមទាំងការតបណ្តាញក្នុងអគារនិងលំនៅដ្ឋាន
- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធជាមួយនឹងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៃការបញ្ជូននិងចែកចាយថាមពលអគ្គិសនីព្រមទាំងការតបណ្តាញក្នុងអគារនិងលំនៅដ្ឋាន
- សម្របសម្រួលការងាររដ្ឋបាលជាមួយគ្រប់ការិយាល័យក្នុងនាយកដ្ឋាន
- ទទួលបន្ទុកនិងគ្រប់គ្រងរាល់ឯកសាររដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំតាក់តែងរាល់លិខិតរដ្ឋបាលរបស់នាយកដ្ឋាន
- រៀបចំគម្រោងផែនការតម្រូវការសម្ភារៈបរិក្ខារនិងផែនការសកម្មភាពប្រចាំឆ្នាំរបស់នាយកដ្ឋាន
- រៀបចំកម្មវិធី របៀបរបបធ្វើការងារ និងកិច្ចប្រជុំផ្សេងៗសម្រាប់នាយកដ្ឋាន
- បណ្តុះបណ្តាលមន្ត្រីចូលបម្រើការងារថ្មីលើការងាររដ្ឋបាល
- រៀបចំកិច្ចប្រជុំផ្ទៃក្នុងនាយកដ្ឋានជាប្រចាំនិងធ្វើរបាយការណ៍
- បូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ៩ខែ និងប្រចាំឆ្នាំរបស់នាយកដ្ឋាន
- គ្រប់គ្រង ផ្គត់ផ្គង់ បែងចែកនិងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈបរិក្ខារការិយាល័យរបស់នាយកដ្ឋាន
- គ្រប់គ្រងសណ្តាប់ធ្នាប់និងអនាម័យរបស់នាយកដ្ឋាន
- តាមដានបញ្ជីវត្តមានរបស់មន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាក្នុងនាយកដ្ឋាន និង
- តាមដាន ត្រួតពិនិត្យ និងរៀបចំបែបបទស្នើតាំងស៊ប់ក្នុងក្របខណ្ឌ ដំឡើងថ្នាក់ ឋានន្តរស័ក្តិ គ្រឿងឥស្សរិយយសនិងពង្រឹងវិន័យក្នុងនាយកដ្ឋាន។

ការិយាល័យផែនការនិងអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- ប្រមូលធ្នុំព័ត៌មាននិងទិន្នន័យនៃការផ្គត់ផ្គង់អគ្គិសនីនិងចូលរួមរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី
- ចូលរួមផ្តល់យោបល់ក្នុងការសិក្សានិងការអនុម័តផែនការមេដើម្បីអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី
- ចូលរួមរៀបចំផែនការនិងកម្មវិធីវិនិយោគគម្រោងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី
- ចូលរួមជំរុញវិនិយោគិនឱ្យចូលរួមវិនិយោគ ត្រួតពិនិត្យ និងវាយតម្លៃលើសំណើសុំគោលការណ៍អនុញ្ញាតធ្វើការសិក្សាសមិទ្ធិលទ្ធភាពនៃគម្រោងអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី
- សហការជាមួយនាយកដ្ឋានអភិវឌ្ឍថាមពលក្នុងការងាររៀបចំជ្រើសរើសអ្នកវិនិយោគ គោលការណ៍អនុញ្ញាតឱ្យវិនិយោគ ត្រួតពិនិត្យការសាងសង់ និងការប្រគល់ទទួលនៃគម្រោងអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី
- គ្រប់គ្រង តាមដាន ព័ត៌មាន ទិន្នន័យ ប្រសិទ្ធភាព និងលក្ខណៈបច្ចេកទេស នៃកិច្ចដំណើរការប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដែលបានអភិវឌ្ឍរួច និង

- ចូលរួមកិច្ចសហប្រតិបត្តិការក្នុងតំបន់និងអន្តរជាតិពាក់ព័ន្ធនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី។

ការិយាល័យគោលនយោបាយអាជីវកម្មផ្គត់ផ្គង់ជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- កំណត់យុទ្ធសាស្ត្រនិងផែនការពង្រីកវិសាលភាពនៃការផ្តល់សេវាកម្មផ្គត់ផ្គង់អគ្គិសនី
- សិក្សានិងកំណត់គោលនយោបាយនិងយន្តការនៃការធ្វើអាជីវកម្មក្នុងប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញជាតិ រវាងអគ្គិសនីកម្ពុជានិងវិស័យឯកជនដើម្បីផ្តល់លទ្ធភាពឱ្យអគ្គិសនីកម្ពុជាទ្រទ្រង់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ) ក្នុងការធ្វើឧបត្ថម្ភធនក្នុងវិស័យ (cross-subsidy) ដើម្បីបន្ថយតម្លាតថ្លៃអគ្គិសនីនិងក្នុងការផ្ទេរទុនដើម្បីយកទៅជួយអភិវឌ្ឍនៅតំបន់ដាច់ស្រយាល ដែលអាជីវកម្មពុំមានប្រសិទ្ធភាពសេដ្ឋកិច្ច
- សហការជាមួយអាជ្ញាធរអគ្គិសនីកម្ពុជានិងអគ្គិសនីកម្ពុជារៀបចំគោលនយោបាយនិងផែនការបន្ថយថ្លៃអគ្គិសនីព្រមទាំងយន្តការឧបត្ថម្ភធនក្នុងវិស័យ (cross-subsidy)
- សិក្សានិងកំណត់គោលនយោបាយនិងផែនការពង្រឹងការផ្តល់សេវាកម្មអគ្គិសនីដូចជាការផ្តល់ភាពគ្រប់គ្រាន់ ការផ្តល់គុណភាព សុវត្ថិភាព និងភាពអាចទុកចិត្តបាន ការផ្តល់ថ្លៃសមរម្យ ការផ្តល់ភាពយុត្តិធម៌ក្នុងការវាស់វែងនិងកត់ត្រា ។ល។ និង
- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តគោលនយោបាយនិងផែនការពង្រឹងការផ្តល់សេវាកម្មខាងលើ។

ការិយាល័យការងារប្រសិទ្ធភាពនិងសន្សំសំចៃថាមពលជាសេនាធិការឱ្យថ្នាក់ដឹកនាំនាយកដ្ឋានដោយមានភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ យុទ្ធសាស្ត ផែនការ និងកម្មវិធីពាក់ព័ន្ធជាមួយនឹងប្រសិទ្ធភាពថាមពលនិងការសន្សំសំចៃថាមពល
- រៀបចំបទប្បញ្ញត្តិពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពលនិងការសន្សំសំចៃថាមពល
- ធ្វើកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិពាក់ព័ន្ធនឹងប្រសិទ្ធភាពថាមពល និងការសន្សំសំចៃថាមពលនិង
- ចូលរួមណែនាំនិងអនុវត្តកម្មវិធីគម្រោងប្រសិទ្ធភាពថាមពលនិងការសន្សំសំចៃថាមពល។

ជំពូកទី៩
អវសានប្បញ្ញត្តិ

ប្រការ២៧ ..

ប្រកាសលេខ០០១៥ រថ.បល.ប្រក ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានចំណុះអគ្គនាយកដ្ឋានថាមពល និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

ប្រការ២៨ ..

នាយកខុទ្ទកាល័យ អគ្គាធិការ អគ្គនាយក ប្រធាននាយកដ្ឋាន ប្រធានមន្ទីរអ៊ែនិងថាមពលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៣កើតខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០១៨
រដ្ឋមន្ត្រីក្រសួងអ៊ែនិងថាមពល

ស៊ុយ សែម

កន្លែងទទួល :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ២៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ០៣២១.ឧក.រស.ប្រក ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ២០១៨

អង្គការលេខរបស់អគ្គនាយកដ្ឋានថាមពល

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី